# សង្ខេបកថា

សូមក្រាបថ្វាយបង្គំព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រមទាំងព្រះរតនត្រ័យជាទីគោរពសក្ការៈ។ សូមគារវៈព្រះថេរានុថេរៈគ្រប់ព្រះអង្គ។ សូមចំរើនពរញាតិញោមពុទ្ធបរិស័ទ ក្រុមគ្រួសារសពនិងភ្ញៀវកិត្តយសទាំងអស់ដែលមានវត្តមាននៅទីនេះ ជាទីមេត្រី។

ព្រះតេជគុណជាទីសក្ការៈ ញាតិញោមទាំងអស់ជាមេត្រី ទិវានេះគឺជាទិវាមួយដែលយើងទាំងអស់គ្នាពោរពេញទៅដោយសេចក្តីរន្ធត់តក់ស្លុតដែលមិននឹកស្មានដល់។ យើងបានមកជួបជុំគ្នាក្នុងទីនេះ សុទ្ធសឹងតែពាំនូវសេចក្តីទុក្ខក្រៀមក្រំ។ យើងទាំងអស់ពិតជាយល់នឹងដឹងច្បាស់ដោយខ្លួនឯង លើកលែងតែលោកតាមហាឧបាសក**អ៊ុំង ខាន់** ម្នាក់ប៉ុណ្ណោះ ដែលយើងមិនដឹងថា តើលោកតាមហាឧបាសកទទួលដឹងនូវភាពក្រៀមក្រំរបស់យើងទាំងអស់គ្នាយ៉ាងណានោះទេ?

លោកតាមហាឧបាសកពោរពេញទៅដោយកុសលធម៌ ទន់ភ្លន់គ្រប់ឥរិយាបថទាំងអស់នោះ កំពុងតែសម្រានយ៉ាងស្ងប់ស្ងាត់នៅចំពោះមុខយើងទាំងអស់គ្នា។ តើលោកតាដឹងទេថា យើងទាំងអស់គ្នាមកជួបជុំគ្នានៅទីនេះ ទាមទារឱ្យលោកកុំទៅចោលយើងទាំងអស់គ្នា យើងទាំងអស់គ្នាមិនចង់ឱ្យលោកឈានជើង ឬហោះហើរទៅណាចាកចេញពីយើងទាំងអស់គ្នា តែធ្វើម្តេចបានបើព្រះសម្មាសម្ពុទ្ធប្រៀបធៀបមនុស្សយើងទៅនឹងឆ្នាំងដី ដែលជាងឆ្នាំងបានធ្វើហើយ តែងតែនឹងបែកប្រេះទៅវិញជាធម្មតាយ៉ាងណា លោកតាក៏គង់តែនឹងបែកចេញពីយើងទាំងអស់គ្នាដែរ។ តែអ្វីដែលយើងក្រៀមក្រំនោះ កូនៗ ចៅៗ ព្រមទាំងញាតិមិត្តពុទ្ធបរិស័ទទាំងអស់នឹងគ្មានឱកាសបានឃើញព្រះភក្តិ អាកប្បកិរិយាទន់ភ្លន់ និងពាក្យអប់រំទូន្មានល្អៗពីលោកតាទៀតទេ។

ព្រះថេរានុថេរៈជាគារវៈ ញាតិញោមពុទ្ធបរិស័ទនិងក្រុមគ្រួសារសពជាទីមេត្រី អាត្មាភាពសោកស្តាយលោកតាមហាឧបាសកអ៊ុង ខាន់ណាស់។ អាត្មាធ្លាប់បានជួបលោកតាពីរឬបីដងនៅឯវត្ត លោកតាមានចំណេះដឹងច្រើនក្នុងព្រះពុទ្ធសាសនា ហើយហាក់ដូចជាមានសមាធិចិត្តជាច្រើន ព្រោះលោកតាមិនដែលភ្លេចរឿងអតីតកាល រឿងថ្ងៃសីលថ្ងៃឧបោសថឡើយ។ ក្នុងឱកាសពិធីបុណ្យចំរើនព្រះជន្មាយុរបស់លោកតា លោកតាបាននិយាយាជូនពរជ័យដល់កូនចៅព្រមទាំងអ្នកចូលរួម បានយ៉ាងក្បោះក្បាយ និងប្រកបដោយអត្ថន័យដ៏ជ្រាលជ្រៅ។ ក្តីចងចាំនិងពលំកាយរឹងប៉ឹងរបស់លោកតា ក្នុងវ័យជាង១០០ឆ្នាំនោះ បានធ្វើឱ្យអាត្មាចងចាំនិងអួលណែនឱរាពេលនឹកឃើញនិងសំលឹងឃើញរូបកាយលោកតាដេកនៅស្តូកស្តឹងឥតមានកំរើកនៅទីនេះ។ តែធ្វើម្តេចទៅ ទោះបីស្តេចចក្រពត្តិ ឬវត្ថុសក្តិសិទ្ធិដែលយើងតែងជឿថាមានបុណ្យបារមីខ្លាំងប៉ុណ្ណា ក៏មិនអាចបញ្ឈៀសលោកតាកុំឱ្យស្លាប់ ឬជប់លោកតាឱ្យរស់រានមានជីវិតឡើងវិញបានឡើយ។ ដូចដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា " ទោះអ្នកជាមនុស្សសាមញ្ញ អ្នកសុំទានគេឬមហាសេដ្ឋី ល្ងង់ឬឆ្លាត ខ្ពស់ឬទាបអាក្រក់ឬស្អាត ព្រះព្រហ្មឬយក្សអសុរី សុទ្ធតែស្ថិតក្រោមច្បាប់នៃអនិច្ចំ ទុក្ខំ និងអនត្តាទាំងអស់" ។

អនិច្ចំឈ្មោះថាមិនទៀង  កើតហើយល្អៀងស្លាប់ទៅវិញ
ទុក្ខំតែងទោម្នេញ  អោយលោកអ្នកស្រក់ទឹកភ្នែក
អនត្តាមិនមែនខ្លួន  កូនមាសស្ងួនមិនអាចជ្រៀតជ្រែក
កើតចាស់ឈឺស្លាប់  ជាច្បាប់ពិតលើលោកា ។

ព្រះសម្មាសម្ពុទ្ធសំដែងថា “ ធម៌ណាដែលមានឈ្មោះអនិច្ចតាធម៌ គឺសភាពប្រែប្រួលមិនទៀងទាត់ អនិច្ចតាធម៌នេះ មិនមែនជាធម៌សំរាប់អ្នកស្រុកតែមួយៗទេ មិនមែនជាធម៌សំរាប់អ្នកនិគមតែមួយៗទេ ឬនឹងថាជាធម៌សំរាប់ត្រកូលតែមួយៗក៏មិនមែនទេ ។ អនិច្ចតាធម៌នេះ ជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតា មារព្រហ្មទាំងអស់គ្រប់រូប” ។ “ ធម៌ណាដែលមានឈ្មោះទុក្ខតាធម៌ គឺសភាពជាទុក្ខ ទុក្ខតាធម៌នេះ មិនមែនជាធម៌សំរាប់អ្នកស្រុកតែមួយៗទេ មិនមែនជាធម៌សំរាប់អ្នកនិគមតែមួយៗទេ ឬនឹងថាជាធម៌សំរាប់ត្រកូលតែមួយៗក៏មិនមែនទេ ។ ទុក្ខតាធម៌នេះ ជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតា មារព្រហ្មទាំងអស់គ្រប់រូប” ។ “ ធម៌ណាដែលមានឈ្មោះអនត្តាធម៌ គឺសភាពមិនមែនជារបស់ខ្លួន អនត្តាធម៌នេះ មិនមែនជាធម៌សំរាប់អ្នកស្រុកតែមួយៗទេ មិនមែនជាធម៌សំរាប់អ្នកនិគមតែមួយៗទេ ឬនឹងថាជាធម៌សំរាប់ត្រកូលតែមួយៗក៏មិនមែនទេ ។ អនត្តាធម៌នេះ ជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប” ។

ខណៈនេះយើងឃើញយ៉ាងប្រត្យក្សថា លោកតាមហាឧបាសកអ៊ុង ខាន់ កំពុងដេកស្តូកស្តឹង ស្ងប់ស្ងាត់ ហាក់ដូចជាមិនអើពើរនឹងពាក្យសំដីអង្វរករនិងទុក្ខក្រៀមក្រំរបស់យើងទាំងអស់គ្នាសោះ ។ នេះជាសភាពពិតនៃជីវិត ដែលប្រកបដោយសង្ខារធម៌ទាំងឡាយប្រាំ មានរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ពេលនេះវេទនា សញ្ញា សង្ខារនិងវិញ្ញាណ របស់លោកតាបានឃ្លាតឆ្ងាយទៅអស់ហើយ សល់នៅតែរូបធាតុ ដែលយើងមើលឃើញសុទ្ធតែផ្សំឡើងដោយធាតុទឹក ធាតុដី ធាតុភ្លើង និងធាតុខ្យល់ ហើយនៅមិនយូរ តែប៉ុន្មានទាទីខាងមុខនេះ ធាតុទាំងបួននេះនឹងរត់ទៅរកធាតុដើមរបស់គេវិញទាំងអស់ ។

ព្រះថេរានុថេរៈ ញាតិញោមពុទ្ធបរិស័ទ និងក្រុមគ្រួសារសព មនុស្សយើងទាំងអស់គ្នាមិនខុសពីលោកតាទេ បើខុសក៏ខុសត្រង់លោកតាមានបុណ្យច្រើន ដែលមានអាយុរហូតដល់១០៤ឆ្នាំ ទើបធ្វើមរណកាលទៅ តែអ្វីដែលដូចគ្នានោះគឺពេលយើងស្លាប់ទៅ យើងមិនអាចយកអ្វីទៅជាមួយបានឡើយ ។ កូនជាទីស្រលាញ់ ចៅជាទីស្រលាញ់ ឬមាសពេជ្រកែវកងច្រើនយ៉ាងណាក៏ដោយ នឹងនៅសល់ ក្លាយជារបស់អសាបង់ឥតន័យឥតខ្លឹមសារ ។ ប៉ុន្តែអ្វីដែលលោកតាអាចយកទៅបាននៅពេលនេះ គឺអំពើជាបុណ្យជាកុសល និងគុណធម៌ដែលលោកតាបានសន្សំក្នុងរយះពេលកន្លងមក ។ ដូចយើងដឹងស្រាប់ហើយថា លោកតាធ្លាប់បានសាងព្រះផ្នួសជាបព្វជិតសន្សំបុណ្យសន្សំកុសលអស់រយះពេលជាច្រើនព្រះវស្សា ។ ហើយក្នុងឆាកជីវិតរបស់លោកតា ប្រកបមុខរបរចិញ្ចឹមជីវិតតាមសម្មាអាជីវៈ ចិញ្ចឹមកូនចៅដោយទំនួលខុសត្រូវ និងទទួលភារៈ

ជួយដល់អ្នកដទៃនិងសង្គមថែមទៀតផង ។ សេចក្តីស្លាប់គឺទៀងទាត់ តែជីវិតរបស់យើងម្នាក់ៗគឺមិនទៀងទាត់ទេ ដូច្នេះមានតែខំកសាងអំពើល្អ ដូចដែលមានលោកតាមហាឧបាសកអ៊ុង ខាន់ ជាគំរូស្រាប់ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា " **ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ** ដែលប្រែជាន័យសេចក្តីបានថា *រូបកាយរលត់រលាយទៅ កេរ្តិ៍ឈ្មោះនៅឥតរសាយ ល្អនិងអាក្រក់ឮវែងឆ្ងាយ គួរស្តាយខំសាងអំពើល្អ* ។

ហើយម្យ៉ាងវិញទៀត កូនដែលជាមាសស្ងួនរបស់ឪពុក គួរតែចិញ្ចឹមមើលការខុសត្រូវ ទំនុកបំរុងមាតាបិតាពេលដែលគាត់ចាស់ជរាទៅ ជាពិសេសកូនចៅត្រូវតែថែទាំងមាតាបិតា ចិញ្ចឹមបីបាច់ និងធ្វើបុណ្យឱ្យគាត់ឱ្យបានច្រើន នៅពេលដែលនៅមានជីវិតនៅឡើយ ។ កូនចៅទាំងអស់ត្រូវតែដឹងឱ្យច្បាស់ថាមាតាបិតាគឺជាព្រះពិតរបស់យើងទាំងឡាយ ហើយយើងគួរតែទំនុកបំរុងនិងធ្វើបុណ្យឱ្យគាត់នៅពេលដែលគាត់នៅមានជីវិតនៅឡើយ ដូចដែលបណ្ឌិតអ៊ូ ចុង ដែលជាអ្នកតែងកំណាព្យដ៏ល្បីល្បាយម្នាក់របស់ខ្មែរបានពោលថា

| | | |
|---|---|---|
| | ព្រះពុទ្ធដាក់ឈ្មោះ | |
| បាលីពីរោះ | បុព្វទេវា | " ទេវតាខាងដើម" |
| អ្នកផ្តើមរក្សា | បុត្រីបុត្រា | ហៅទេវតាផ្ទះ ។ |
| | គឺម្តាយឪពុក | |
| ជាអ្នកម្ចាស់ស្រុក | កូនមិនសំពះ | ម៉ែឪទូន្មាន |
| ឈ្លានពានចង់ឈ្នះ | សត្រូវនឹងព្រះ | កន្លោងអាត្មា ។ |
| | ប្រទូសរ៉ាយ | |
| នឹងឪពុកម្តាយ | ស្រែកហៅទេវតា | អំពីខាងក្រៅ |
| ដឹងនៅឯណា | ឈ្លោះនឹងទេវតា | គឺម៉ែឪឯង ។ |
| | តែងតែលំបាក | |
| ក្រីក្រគោកយ៉ាក | ជាតិនេះឃើញស្តែង | ហើយទៅរងទុក្ខ |
| ខាងមុខពុំលែង | លុះភ័យទើបស្វែង | រកហោរគ្រូទាយ ។ |

ម្យ៉ាងទៀតរឿងធ្វើបុណ្យបុត្រាបុត្រីគួរយល់ឱ្យច្បាស់ដូចនេះគឺ......

| | | |
|---|---|---|
| ត្រូវធ្វើបុណ្យខ្មើត | ម៉ែឪហូបកើត | កំពុងស្រេកឃ្លាន |
| ម៉ែឪនៅរស់ | កូនត្រូវធ្វើទាន | បំបាត់ក្តីឃ្លាន |
| | ហៅធ្វើបុណ្យខ្មើត ។ | |

ហៅបុណ្យខែភ្លឺ កុំចាំគាត់ឈឺ បរិភោគលែងកើត
ជូនគាត់កាលជា ហៅថាបុណ្យខ្មើត គាត់បរិភោគកើត
បានជាងរនោច ។
លុះបាត់ជីវិត បុណ្យខែងងឹត ដូចថ្ងៃ១០រោច
កូចចៅទាំងឡាយ យកបាយឱ្យខ្មោច ម៉ែឥតប្រយោជន៍
ខ្មោចណាចេះស៊ី ។

ម្យ៉ាងទៀតធ្វើបុណ្យ ច្រើនតែចោលគុណ គ្មានគិតរិះរេ
បោលទៅតែវត្ត ម្តាយអត់ទទេ ព្រោះជឿតាមគេ
រកបុណ្យខាងក្រៅ ។
ដើមបុណ្យលើផ្ទះ ខ្លួនកើតទាន់ព្រះ កន្លោងគង់នៅ
បានត្រីត្រកាល ទុកក្បាលឱ្យឪ កណ្តាលនាំទៅ
យកបុណ្យឯវត្ត ។

នេះហៅបុណ្យខុស ទាំងស្រីទាំងប្រុស ខ្ញុំប្រាប់កុំខឹង
ម៉ែឪនៅរស់ ចូរអស់លោកប្រឹង ធ្វេញគាត់នៅរឹង
បានឆ្ងាញ់ពិសា ។
ខ្លះជឿបុណ្យខ្លាំង យួរម្ហូបទាំងឆ្នាំង យកទៅវត្តវ៉ា
ម៉ែឪអត់ឃ្លាន ចង់បានណាស់ណា ភ្លួយសួរកូនថា
មានសល់ឬទេ? ។
ព្រឹកឡើងឃ្លានបាយ ញ័រពោះញើសខ្វាយ ឃើញសម្លគេ
កូនឆ្លើយរឹងថ្កាន មិនបានសល់ទេ ខ្ញុំស្ទួគ្រាន់តែ
ទៅវត្តទេឪ ។
ឪពុកសួរថា បើជួសកាលណា ចែកឪខ្លះទៅ
កូនខ្លះឆ្លើយប្រាប់ ថាបាបណាស់ឪ គេថាមិនត្រូវ
ឪស៊ីមុនលោក ។
ម៉ែឪចាស់ៗ ព្រឹកឡើងឃ្លានណាស់ គួរឱ្យវិយោគ

ឪទារពិសា　កូនថាមុនលោក　ពុំបានបរិភោគ
គេឱ្យបាបផង ។
នេះបុណ្យផ្ទាប់មុខ　ឬបុណ្យចោលស្រុក　ព្រោះដើរផ្លូវឆ្គង
បុណ្យមិនត្រកាល　វិសាលឡើយហោង　ព្រោះដើរកន្លង
ឱ្យម៉ែឪអត់ ។
ពួកជនឈ្លានពាន　មិនចេះធ្វើទាន　ច្រើនធ្វើទានក្បត់
សទ្ធាមិនជ្រៅ　ជ្រុលទៅតែវត្ត　ឱ្យព្រះដើមអត់
ស្រែកឃ្លានពេកក្រៃ ។

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ញាតិញោមពុទ្ធបរិស័ទ ភ្ញៀវកិត្តយស និងក្រុមគ្រួសារសព ទាំងឡាយ ពេលនេះនៅសល់តែប៉ុន្មាននាទីទៀតប៉ុណ្ណោះ រូបរាងកាយរបស់ញោម លោកតាមហា ឧបាសកអ៊ុង ខាន់នឹងរលត់ពីភ្នែករបស់យើងទាំងឡាយហើយ អ្វីដែលបន្សល់ទុកឱ្យយើងចងចាំជិតជាប់ក្នុង បេះដូងនិងជិតជាប់ក្នុងនេត្រានោះគឺបណ្តាំដែលធ្លាប់បានផ្តាំអោយកូនៗស្រលាញ់គ្នា និងថែរក្សាគ្នាទៅវិញ ទៅមក។ សូមឱ្យកូនចៅទាំងអស់ ស្រង់យកពាក្យពេចន៍ដ៏មានតំលៃនោះ ទុកឱ្យជាប់ក្នុងក្រអៅបេះដូង និងផ្ដិតឱ្យជាប់ក្នុងដួងនេត្រាជារៀងរាបតទៅ។

សូមលោកតាមហាឧបាសក កុំខ្វល់ខ្វាយ, បារម្ភ និងជាប់ជំពាក់ចំពោះកូនៗ ចៅៗ ឬញាតិសន្តានអី។ សូមអោយលោកតាមហាឧបាសកធ្វើដំណើរតាមកុសលផលបុណ្យដែលជាស្ពានដែល បានកសាងហើយ ឆ្ពោះទៅរកទេវស្ថាន សុខសម្រាន្តចិត្តចុះ។ កូនចៅ ញាតិមិត្ត និងយើងខ្ញុំ ទាំងឡាយ នឹងខិតខំសន្សំបុណ្យកុសលឱ្យដូចញោម ដូចលោកតាដែរ។

ដោយអំណាចនៃបុណ្យកុសលដែលលោកតាបានសន្សំហើយ និងបុណ្យកុសលដែលយើងខ្ញុំទាំង ឡាយបានបានសន្សំទុកទាំងប៉ុន្មាន សូមឧទ្ទិសនិងបួងសួងអោយព្រះវិញ្ញាណក្ខន្ធដ៏បរិសុទ្ធិរបស់លោក តាមហាឧបាសក បានទៅសោយសុខគតិភពក្នុងសួគ៌ាវិមាន រហូតបានសម្រេចនូវព្រះនិព្វានជាទី អវសាន្តនៃកងទុក្ខទាំងពួង កុំបីឃ្លៀងឃ្លាតឡើយ ។

មហាឧបាសកអ៊ុង ខាន់មានគុណធំ　ជាម្ចាស់ទ្រទំកូនចៅរាល់គ្នា
កាលលោករស់នៅចិញ្ចឹមរក្សា　កូនគ្រប់អាត្មាសុខសាន្តធាត់ធំ ។
មហាឧបាសកអ៊ុង ខាន់មានព្រហ្មវិហារធម៌　មេត្តាបវរឱ្យបានសុខដុម

ករុណាបីបាច់កូនចៅតូចធំ មុទិតា ឧបត្ថម្ភ ឧបេក្ខាចិត្ត ។
ថ្ងៃនេះកូនចៅសូមបង្គំវន្ទា ដល់គុណករុណាអ្នកម្ចាស់ជីវិត
សូមខមាទោសតូចធំឆ្ងាយជិត សូមគុណធម៌ពិតប្រោសប្រាណប្រណី ។
យើងសូមបួងសួងដល់អស់ទេវតា គុណបុណ្យអស្ចារ្យព្រះពុទ្ធម្ចាស់ថ្លៃ
គុណបុណ្យមេត្តាសច្ចៈខន្តី តេជះបារមីសូមនាំលោកមហាឧបាសកអ៊ុង ខាន់
ទៅរកបរមសុខអើយ ។

ដោយសេចក្តីស្រលាញ់និងគោរពដ៏ខ្ពង់ខ្ពស់ពីអាត្មាភាព ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ញាតិញោមពុទ្ធបរិស័ទ ភ្ញៀវកិត្តយស និងកូនៗចៅៗចៅទួតទាំងឡាយ ។